អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី២

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---:|---:|---:|
| ទ្រព្យសកម្មសរុប | ៣៣.៩៥៦.៧១៨ | ៣២.០០២.២៩៨ | ២៦.៥០០.៧៩៣ |
| បំណុលសរុប | ២៨.៩៩៧.៨៤៧ | ២៧.០៩២.៩៨៥ | ២២.០៩៣.២៥៨ |
| មូលធនសរុប | ៤.៩៥៨.៩៧១ | ៤.៩០៩.៣១៣ | ៤.៤០៧.៥៣៥ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** | **ត្រីមាសទី២ ឆ្នាំ២០២០** |
| ចំណូលសរុប | ៧៥២.០៦៧ | ៦២៥.៥១៧ | ៥៧១.២៤១ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២៤៩.៥១៦ | ១៨៧.៥៨៧ | ១៥៩.២០៣ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៩៥.៨៦៥ | ១៥០.៧៩៦ | ១២៣.៨១៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៥៤.៦៨៩ | ១៧៤.១៥៤ | ១២២.១៣២ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតសាធនភាព | ២០,០៨% | ២២,៣៦% | ២៥,១៥% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៨៤,៧៥% | ៥៥១,៨៧% | ៥០១,២៦% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៣៦,៩១% | ១៥៥,៦៥% | ១៤៩,៣១% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៧៩% | ២,៣៣% | ២,៤០% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៩,៩៥% | ៩៤,៩៧% | ៩៧,៧៣% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១១.៣៩១ | ១១.២៧៧ | ១០.១៧៥ |
| | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** | **ត្រីមាសទី២ ឆ្នាំ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៥៨% | ០,៥២% | ០,៤៩% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ៣,៩៤% | ៣,២៣% | ៣,០៧% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ២,២១ | ២,០៩ | ២,០៣ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៥១,៤៨ | ៣៤៨,៨២ | ២៨៧,៥៥ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# អនុបាតហិរញ្ញវត្ថុ(%)







ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
២៨៧,៥៥
៣៨៨,៨២
៤៥១,៤៨
ត្រីមាសទី២ ឆ្នាំ២០២០
ត្រីមាសទី២ ឆ្នាំ២០២១
ត្រីមាសទី២ ឆ្នាំ២០២២


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១០.១៧៥
១១.២៧៧
១១.៣៩១
ឆ្នាំ២០២០
ឆ្នាំ២០២១
ត្រីមាសទី២ ឆ្នាំ២០២២

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក រ័ត្ន យូម៉េង**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**
*អភិបាលមិនប្រតិបត្តិ*



**លោក Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**
*អភិបាលឯករាជ្យ*



**លោកស្រី ភូរិ រតនា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២២ របស់ធនាគារ គិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដល់ភាគីពាក់ព័ន្ធទាំងអស់។

អតិផរណាជាសកល ដែលរងផលប៉ះពាល់ពីការអូសបន្លាយនៃសង្គ្រាមនៅអ៊ុយក្រែនបាន និងកំពុងបណ្តាលឱ្យមានការកើនឡើងថ្លៃចំណាយប្រចាំថ្ងៃ ការប្រែប្រួលអត្រាប្តូរប្រាក់ ផលប៉ះពាល់លើថ្លៃដើមប្រាក់កម្ចី ។ល។ ការកើនឡើងថ្លៃចំណាយប្រចាំថ្ងៃបានបង្កផលប៉ះពាល់ដល់ប្រជាជនដែលមានចំណូលទាប ដោយការចំណាយលើផលិតផល និងសេវាកម្មកាន់តែថ្លៃ។ បន្ថែមលើនេះ ការកើនឡើងខ្ពស់ជាបន្តបន្ទាប់នូវអតិផរណា អាចបណ្តាលឱ្យស្ថាប័នហិរញ្ញវត្ថុ ត្រូវបង្កើនអត្រាការប្រាក់ ដើម្បីការពារខ្លួនពីសម្ពាធអតិផរណា។

ឆ្លើយតបនឹងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការជាច្រើន ព្រមទាំងបានគ្រោងបញ្ចេញថវិកាដើម្បីកាត់បន្ថយកំណើនអតិផរណា និងរក្សាកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់។ រាជរដ្ឋាភិបាលក៏បានគ្រោងបញ្ចេញថវិកាដើម្បីគាំទ្រ និងស្តារសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្មខ្នាតតូចបំផុត និងខ្នាតតូច ព្រមទាំងក្រុមគ្រួសារ ដែលក្រីក្រ និងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩។ បន្ថែមលើនេះ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ច្បាប់វិនិយោគ និងយុទ្ធសាស្ត្រថ្មីៗ បានក្លាយជាយន្តការដ៏សំខាន់ក្នុងការទាក់ទាញវិនិយោគិនបរទេស និងជំរុញកំណើនការនាំចេញ នៅក្នុងកំលុងឆមាសទី១ នៃឆ្នាំ២០២២នេះ។ បន្ថែមលើនេះ ការបើកព្រំដែនឡើងវិញបានជំរុញឱ្យវិស័យពាណិជ្ជកម្ម និងទេសចរណ៍ងើបឡើងវិញ ជាពិសេស ការកើនឡើង នៃភ្ញៀវទេសចរអន្តរជាតិ ដែលនាំឱ្យមានការកើនឡើងនូវតម្រូវការ សម្រាប់ការស្នាក់នៅ អាហារ ការដឹកជញ្ជូន និងសេវាកម្មដោយផ្ទាល់ផ្សេងៗទៀត។

ជាលទ្ធផល យន្តការទាំងនេះរបស់រាជរដ្ឋាភិបាលបានជួយកាត់បន្ថយអតិផរណា និងជំរុញកំណើនសេដ្ឋកិច្ចយ៉ាងមានប្រសិទ្ធភាព នៅក្នុងកំលុងឆមាសទី១ នៃឆ្នាំ២០២២នេះ។ បន្ថែមលើនេះ វាក៏បានជួយគាំទ្រ និងជំរុញឱ្យធនាគារ និងអតិថិជនភាគច្រើនមានការរីកចម្រើនជាបន្តបន្ទាប់ផងដែរ។

នៅក្នុងកំលុងត្រីមាសទី២ ឆ្នាំ២០២២នេះ ធនាគារបាន និងកំពុងពង្រីកផលិតផល និងសេវាកម្មចម្រុះ ទាំងក្នុង និងក្រៅប្រទេស ដើម្បីឱ្យអតិថិជនធ្វើប្រតិបត្តិការធនាគារបានកាន់តែងាយស្រួល។ ធនាគារបានពង្រីកបណ្តាញសេវាផ្ទេរប្រាក់ឆ្លងប្រទេសដោយសហការជាមួយក្រុមហ៊ុនយក្ស២ផ្សេងទៀត គឺ ក្រុមហ៊ុន MoneyGram និង Thunes បន្ថែមលើក្រុមហ៊ុន Western Union និង SWIFT ដើម្បីសម្រួលអតិថិជនក្នុងការផ្ទេរប្រាក់ដោយផ្ទាល់ពី និង/ឬទៅ អេស៊ីលីដាម៉ូបាល។ ទន្ទឹមនឹងនេះ ធនាគារបានបន្តពង្រីកសេវាកម្មធនាគារ ដោយបំពាក់នូវម៉ាស៊ីនអេធីអឹម ម៉ាស៊ីនឆ្លូតកាត និងសេវាធនាគារស្វ័យប្រវត្តិ ព្រមទាំងបង្កើនសមត្ថភាព អេស៊ីលីដាម៉ូបាល ដើម្បីបម្រើអតិថិជនរបស់ខ្លួនបានឱ្យកាន់តែទូលំទូលាយ និងងាយស្រួល។ បន្ថែមលើនេះ ធនាគារក៏ទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជាភ្នាក់ងារថែរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដែលធ្វើឱ្យធនាគារដើរតួនាទីយ៉ាងសំខាន់ ក្នុងការទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅប្រទេសឱ្យវិនិយោគក្នុងវិស័យមូលបត្រកម្ពុជា។

នៅក្នុងកំលុងត្រីមាសទី២ ឆ្នាំ២០២២នេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

ប្រាក់បញ្ញើសរុបចំនួន ៦.០០៥,៣០លានដុល្លារអាមេរិក បានកើនឡើងចំនួន ២៨៩,២៨លានដុល្លារអាមេរិក (៥,០៦%) ហើយសមតុល្យឥណទានសរុបចំនួន ៦.០០២,៥០លានដុល្លារអាមេរិក បានកើនឡើងចំនួន ៥៧៣,៩៣លានដុល្លារអាមេរិក (១០,៥៧%) បើធៀបនឹងដំណាច់ឆ្នាំ២០២១។

ក្នុងត្រីមាសនេះ ធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារចំនួន ៤៨,១៨លានដុល្លារអាមេរិក ខណៈដែលធនាគារទទួលបានចំណេញធៀបនឹងទ្រព្យសកម្មមធ្យមចំនួន ០,៥៨% និងទទួលបានចំណេញធៀបនឹងមូលធនមធ្យមចំនួន ៣,៩៤%។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃអង្គារ ១២កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២

ហត្ថលេខា និងត្រា

**ឆាយ សឿន**

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ...... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ...... ii

សមាសភាពក្រុមប្រឹក្សាភិបាល ...... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ...... vi

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ...... ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ...... ១**

**ខ- លក្ខណៈនៃធុរកិច្ច ...... ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ...... ១**

**ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ...... ២**

**ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ...... ២**

**ខ- រចនាសម្ព័ន្ធចំណូល ...... ៦**

**ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ...... ៦**

**ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ...... ៧**

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ...... ៧**

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ...... ១០**

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ...... ១២**

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ...... ១២**

**ង- ផលប៉ះពាល់នៃអតិផរណា ...... ១២**

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ...... ១៣**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ...... ១៥**

## ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ កិច្ចជំនួបធុរកិច្ចកម្ពុជា-ជប៉ុន ដែលត្រូវបានរៀបចំសហការដោយ ធនាគារ អេស៊ីលីដា និងសមាគមជប៉ុន-កម្ពុជា (JCA) នៅការិយាល័យកណ្តាលរបស់ធនាគារ មានក្រុមហ៊ុនជប៉ុនចំនួន២៤ក្រុមហ៊ុនបានចូលរួមក្នុងកិច្ចជំនួបធុរកិច្ចនេះ។ ព្រឹត្តិការណ៍ដ៏សំខាន់នេះ អាចទាក់ទាញវិនិយោគិនសក្តានុពល ពីវិស័យផ្សេងៗ ក៏ដូចជា ការនាំមកនូវចំណេះដឹងផ្នែកបច្ចេកទេស និងឱកាសការងារបន្ថែមទៀតដល់កម្ពុជា។
- នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ និងកោតសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី បានចូលរួមចំណែកបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋជាប់លំដាប់ទី៥ ក្នុងចំណោមសហគ្រាសដែលបង់ពន្ធច្រើនជាងគេ ក្នុងឆ្នាំ២០២១។

- នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ធនាគារបានប្រារព្ធពិធីប្រគល់ ទទួលវិញ្ញាបនបត្រទទួលស្គាល់ធនាគារ អេស៊ីលីដា ជាភ្នាក់ងាររក្សាសុវត្ថិភាព ក្នុងវិស័យមូលបត្រ ពីនិយ័តករមូលបត្រកម្ពុជា ដែលធ្វើឱ្យធនាគារក្លាយជាធនាគារពាណិជ្ជទី១ នៅកម្ពុជា ដែលផ្តល់សេវាថែរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។
- នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ធនាគារបានទទួលពានរង្វាន់៣ ពីផ្សារមូលបត្រកម្ពុជា គឺ ពានរង្វាន់ភាគហ៊ុនជួញដូរច្រើនជាងគេប្រចាំឆ្នាំ២០២១ ពានរង្វាន់ភាគហ៊ុនពេញនិយមជាងគេនៅទីផ្សារគោល និងពានរង្វាន់អភិបាលកិច្ចសាជីវកម្មឆ្នើម។
- នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងធនាគារ SMBC បានចុះកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានចំនួន១៣៥លានដុល្លារអាមេរិក ជាមួយធនាគារ អេស៊ីលីដា សម្រាប់ផ្តល់កម្ចីបន្ថែមក្នុងវិស័យកសិកម្មនៅកម្ពុជា។ កិច្ចព្រមព្រៀងនេះនឹងចូលរួមចំណែកក្នុងការលើកកម្ពស់ផលិតផលកសិកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម យ៉ាងពិតប្រាកដ។
- នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ធនាគារបានទទួលវិញ្ញាបនបត្រចុះបញ្ជីជាភ្នាក់ងារថែរក្សាសុវត្ថិភាព សម្រាប់ផ្តល់សេវាថែរក្សាសុវត្ថិភាព ក្នុងវិស័យមូលបត្រ ពីនិយ័តករបរធនបាលកិច្ច។
- នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ធនាគារបានសហការជាមួយ MoneyGram ដែលជាក្រុមហ៊ុនឈានមុខជាសកលមួយក្នុងការធ្វើបដិវត្តទូទាត់បែបឌីជីថល។ តាមរយៈភាពជាដៃគូនេះ បច្ចុប្បន្នអតិថិជនអាចប្រើប្រាស់ អេស៊ីលីដាម៉ូបាល ដែលគាំទ្រដោយប្រព័ន្ធទូទាត់ជាសកលរបស់ក្រុមហ៊ុន MoneyGram និងសមត្ថភាពទូទាត់កាន់តែឆាប់រហ័ស ដើម្បីផ្ញើប្រាក់ទៅ និងទទួលប្រាក់ពីប្រទេសជាង២០០ នៅជុំវិញពិភពលោក។
- នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ធនាគារបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយធនាគារ SME ស្តីពីការអនុវត្តគម្រោងសហហិរញ្ញប្បទាន ដើម្បីគាំទ្រ និងជំរុញការស្តារវិស័យទេសចរណ៍ឡើងវិញ។ គម្រោងនេះមានគោលបំណងផ្តល់ហិរញ្ញប្បទានដល់ម្ចាស់អាជីវកម្មទេសចរណ៍ រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ការផ្គត់ផ្គង់អាហារ និងភេសជ្ជៈ និងការផ្គត់ផ្គង់ផលិតផល/សេវាកម្មផ្សេងៗ សម្រាប់គាំទ្រដល់វិស័យទេសចរណ៍ ដែលមានតម្រូវការឥណទាន ដើម្បីគាំទ្រដល់ការបើក ការកែលម្អ និងការពង្រីកអាជីវកម្មរបស់ពួកគាត់។
- នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ធនាគារបានដាក់ឱ្យដំណើរការផ្ទេរប្រាក់ឆ្លងប្រទេសរបស់ Wstern Union តាមរយៈអេស៊ីលីដាម៉ូបាល ដែលអាចឱ្យអតិថិជនទទួលបានអត្ថប្រយោជន៍ពីបណ្តាញដ៏ធំនេះ នៅជាង២០០ប្រទេស។ បច្ចុប្បន្នអតិថិជនដែលកំពុងប្រើប្រាស់ អេស៊ីលីដាម៉ូបាល អាចផ្ទេរប្រាក់ពី / ទៅកាន់បរទេស នៅគ្រប់ពេលវេលា។ ពួកគាត់អាចផ្ញើ និងដកប្រាក់ នៅជាង២០០ប្រទេសនៅទូទាំងសកលលោក។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

ត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២២ ធនាគារពាណិជ្ជមានចំនួន៥៧ (ធនាគារក្នុងស្រុកចំនួន២៧ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១២) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៥ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨០) ក្រុមហ៊ុនភតិសន្យាចំនួន១៧ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣១ និងគ្រឹះស្ថានឥណទានជនបទចំនួន២៣១។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ**

គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២២ ធនាគារ អេស៊ីលីដា មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៥,៤៣% និងសម្រាប់ឥណទានចំនួន ១៣,៨៦%។

គិតនៅត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២២ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៥៦០.៧២៦ | ៥៤១.១៨៤ | ៥៥៥.៣២៣ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៤.៤៣០.១៨៧ | ២២.១១៦.០១៣ | ១៨.២២៩.៣៧២ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៣.៥៩១.២៩៤ | ៣.២៩៨.៣៨២ | ២.៨៩៤.៩០៧ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៤.៤៤១.៥៥៥ | ២៣.២៨៧.០៦៤ | ១៨.៦៥២.៦៩០ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៧១៦.៩៥៥ | ១.៥៨៥.៤៤៩ | ១.៣៩៦.៧៧៨ |
| ចំនួនប្រតិបត្តិការសរុប | ១០.៣៧១.០៨៨ | ១៩.៤៤៨.៨៣៧ | ១៩.៧៦៨.២២៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៩.៥៨៣.២៧១ | ១៦.១៧៣.៩៩០ | ១៣.៧៧៥.៩១៨ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.៥៩៧.៩៥៥ | ២.២៧៨.២២០ | ១.៧៨២.៨១៤ |
| ចំនួនប្រតិបត្តិការសរុប | ៥៨.៤២៣.៥១៩ | ៧៨.៧២៦.៨៩៥ | ៤៨.៧៤៩.៥៩៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៩៣.៦៨៦.៧១៨ | ១១៥.២៤២.៦៣៨ | ៥៩.២១១.២៧៩ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២១.៦៤៧ | ១៣.៥៥៧ | ១១.៦៧៩ |
| ចំនួនប្រតិបត្តិការសរុប | ១.០៤២.៥៦៨ | ១.៤៦៦.៨២២ | ៨៨៦.៩៩០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១២.៩៤៩.៦៧៩ | ១៩.៧៩៩.៨៦៤ | ១១.២៨៥.៩៤៨ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| **អេស៊ីលីដាអ៊ិខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៦០ | ៥៩ | ៥១ |
| ចំនួនប្រតិបត្តិការសរុប | ១.៧៨៦.០១១ | ៣.២១៥.២០៧ | ៤៤៧.៩២៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៩១០.៤៥៧ | ១.២០៦.៥២៩ | ៣៦០.០០០ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.០៨១ | ៩០១ | ៧៥៧ |
| ចំនួនប្រតិបត្តិការសរុប | ១៦.៥២៣.៥៨៤ | ២៧.១២៩.២៥២ | ២៦.៥៧២.៧៧១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨.៧៤២.៨៤២ | ២៦.៤៧៧.៣៨១ | ២០.០១៨.៤៣២ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ១.០៤២ | ៤.១២០ | ១.៩០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨០.៧៤៣ | ៣៤៣.១៥៨ | ១៨០.២៩២ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៤ | ២៥ | - |
| ចំនួនប្រតិបត្តិការសរុប | ២១.៨១៣ | ៣៤.០៩២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤ | ៧០ | - |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១២ | ១៤ | ១៩ |
| ចំនួនប្រតិបត្តិការសរុប | ៣៦.៥៣៧ | ៩៤.៧១៣ | ១២១.១៩៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៨៦.៩៩៧ | ៥៥៥.២៥៧ | ៨៣០.៤០៨ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.៥៨៦ | ៤.៤៦២ | ៤.២៨៧ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| ចំនួនប្រតិបត្តិការសរុប | ១.១៥៥.០៨៥ | ២.០៣៣.២៨៣ | ២.៤៥៧.៦២៦ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣០៣.១២៨ | ៤៧៩.៦១៣ | ៦៥៧.៥០៦ |
| **កូដ QR នៅតាមហាងទំនិញនានា** | | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ១៨៨.៦៧៧ | ១២៥.៣០៩ | ៦៣.៧១៤ |
| ចំនួនប្រតិបត្តិការសរុប | ៤.៣៤១.៤០២ | ៣.១៩៤.៤៤៣ | ១.៨៤២.៩១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.០៦៩.០១៣ | ៦៣៨.២៤០ | ១៨៦.៦៩១ |
| **អេស៊ីលីដាអ៊ីសប** | | | |
| ចំនួនផ្សារអនឡាញ | ៣ | ១ | - |
| ចំនួនប្រតិបត្តិការសរុប | ៧ | ២៨៦ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ០,១៧ | ៧ | - |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ៤.០៧៩ | ៣.៦៨៤ | - |
| ចំនួនប្រតិបត្តិការសរុប | ៩.៦៦០ | ២.៤៩១ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៧៤៣ | ១៦១ | - |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៣ | ២៦២ | ២៦៣ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ៩៤ | ៧៣ | ៣៧ |
| ចំនួនបុគ្គលិកសរុប | ១២.១០៩ | ១២.០៨១ | ១២.០១៣ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៧ | ៥៦ |
| ចំនួនបុគ្គលិកសរុប | ១.៥៣៤ | ១.៥៩៣ | ១.៦៩១ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | | ត្រីមាសទី២ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៦៦៩.៤៣២ | ៨៩,០១% | ៥៧០.១២៦ | ៩១,១៤% | ៥១២.១៧៦ | ៨៩,៦៦% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៩.៣៤៨ | ៦,៥៦% | ៣៨.៤៣០ | ៦,១៤% | ៤១.៣៣៤ | ៧,២៤% |
| ៣ | ចំណូលផ្សេងៗ | ៣៣.២៨៧ | ៤,៤៣% | ១៦.៩៦១ | ២,៧១% | ១៧.៧៣១ | ៣,១០% |
| **ចំណូលសរុប** | | **៧៥២.០៦៧** | **១០០%** | **៦២៥.៥១៧** | **១០០%** | **៥៧១.២៤១** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនកររងករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនកររងករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | | ត្រីមាសទី២ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៦៦៩.៤៣២ | ៨៩,០១% | ៥៧០.១២៦ | ៩១,១៤% | ៥១២.១៧៦ | ៨៩,៦៦% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៩.៣៤៨ | ៦,៥៦% | ៣៨.៤៣០ | ៦,១៤% | ៤១.៣៣៤ | ៧,២៤% |
| ៣ | ចំណូលផ្សេងៗ | ៣៣.២៨៧ | ៤,៤៣% | ១៦.៩៦១ | ២,៧១% | ១៧.៧៣១ | ៣,១០% |
| | **ចំណូលសរុប** | **៧៥២.០៦៧** | **១០០%** | **៦២៥.៥១៧** | **១០០%** | **៥៧១.២៤១** | **១០០%** |

ចំណូលសរុបចំនួន ៧៥២,០៧ ប៊ីលានរៀល ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៨៩,០១% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ១២៦,៥៥ ប៊ីលានរៀល ឬ ២០,២៣% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២១។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | ត្រីមាសទី២ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៦៦៩.៤៣២ | ៥៧០.១២៦ | ៩៩.៣០៦ | ១៧,៤២% |
| ចំណាយការប្រាក់ | (២០៥.៣៦៩) | (១៧១.៧១៧) | (៣៣.៦៥២) | ១៩,៦០% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៦៤.០៦៣** | **៣៩៨.៤០៩** | **៦៥.៦៥៤** | **១៦,៤៨%** |
| ចំណូលកម្រៃនិងជើងសា | ៤៩.៣៤៨ | ៣៨.៤៣០ | ១០.៩១៨ | ២៨,៤១% |
| ចំណាយកម្រៃនិងជើងសា | (៣.៩៧៨) | (១.៨៧៩) | (២.០៩៩) | ១១១,៧១% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤៥.៣៧០** | **៣៦.៥៥២** | **៨.៨១៨** | **២៤,១២%** |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួលផ្សេងៗ និងមូលបត្រវិនិយោគ | (៨.៦៣៧) | (២៦.១១៣) | ១៧.៤៧៦ | (៦៦,៩២%) |
| (សំវិធានធនលើ)/ការកត់ត្រាត្រលប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (២) | ៤ | (៦) | ១៥០% |
| **ចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៨.៦៣៩)** | **(២៦.១០៩)** | **១៧.៤៧០** | **(៦៦,៩១%)** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **៥០០.៧៩៤** | **៤០៨.៨៥២** | **៩១.៩៤២** | **២២,៤៩%** |
| ចំណូលផ្សេងៗ | ៣៣.២៨៧ | ១៦.៩៦១ | ១៦.៣២៦ | ៩៦,២៦% |
| ចំណាយទូទៅនិងរដ្ឋបាល | (២៨៤.៥៦៤) | (២៣៨.២២៦) | (៤៦.៣៣៨) | ១៩,៤៥% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៤៩.៥១៦** | **១៨៧.៥៨៧** | **៦១.៩២៩** | **៣៣,០១%** |

ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញនៅត្រីមាសទី២ ឆ្នាំ២០២២ បានកើនឡើងចំនួន ៦១,៩៣ ប៊ីលានរៀល ឬ ៣៣,០១% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២១ ដោយសារភាគច្រើនមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ៦៥,៦៥ ប៊ីលានរៀល ចំណូលកម្រៃនិងជើងសាសុទ្ធចំនួន ៨,៨២ ប៊ីលានរៀល និងចំណូលផ្សេងៗចំនួន ១៦,៣៣ ប៊ីលានរៀល ខណៈដែលចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធថយចុះចំនួន ១៧,៤៧ ប៊ីលានរៀល និងកាត់បន្ថយដោយការកើនឡើងនូវចំណាយទូទៅនិងរដ្ឋបាលចំនួន ៤៦,៣៤ ប៊ីលានរៀល។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | ត្រីមាសទី២ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៤៩.៥១៦** | **១៨៧.៥៨៧** | **៦១.៩២៩** | **៣៣,០១%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៥៣.៦៥១) | (៣៦.៧៩១) | (១៦.៨៦០) | ៤៥,៨៣% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៩៥.៨៦៥** | **១៥០.៧៩៦** | **៤៥.០៦៩** | **២៩,៨៩%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ | ត្រីមាសទី២ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៩៥.៨៦៥** | **១៥០.៧៩៦** | **៤៥.០៦៩** | **២៩,៨៩%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | (១០.៤៣៦) | (៨៤៨) | (៩.៥៨៨) | (១.១៣០,៦៦%) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ១៩៩ | ៣៤.៥៥៩ | (៣៤.៣៦០) | (៩៩,៤២%) |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (៣៩.១៨៣) | (១០.៣៩៣) | (២៨.៧៩០) | (២៧៨,០៨%) |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | ៨.២០៤ | - | ៨.២០៤ | - |
| **លទ្ធផលចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៤១.១៧៦)** | **២៣.៣៥៨** | **(៦៤.៥៣៤)** | **(២៧៦,២៨%)** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៥៤.៦៨៩** | **១៧៤.១៥៤** | **(១៩.៤៦៥)** | **(១១,១៨%)** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេល ៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត អេស៊ីលីដាម៉ូបាល និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន

សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

សម្រាប់រយៈពេល៣០ឆ្នាំខាងមុខ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជា ធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារនឹងអនុវត្តបានកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២២ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ Disaster Recovery Data Center នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសវិស័យ SME។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣១៩ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន៩៤ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.០៨១គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន២៤គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១២គ្រឿង និង**ម៉ាស៊ីនឆូតកាត**ចំនួន៤.៥៨៦គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺធនាគារ អេស៊ីលីដា បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន១,៧២លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ២,៦០លាននាក់ នៅដំណាច់ខែមិថុនា ឆ្នាំ២០២២នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ីនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អ

ដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ **អេស៊ីលីដាអ៊ីសប** គឺជាទម្រង់ផ្សារអនឡាញ ដែលបានបង្កើតឡើងនៅក្នុង **អេស៊ីលីដាម៉ូបាល** សម្រាប់សាធារណជន ទិញ-លក់ផលិតផល សេវាកម្ម និងធ្វើការទូទាត់ភ្លាមៗ។

**KHQR** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**) ។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជា បានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជាៈ សាធនភាព ទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃ ដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុន បុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២០ ដល់២០២១ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារដែលបានបង់ពន្ធដារច្រើនបំផុតលំដាប់ទី៥ ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២១។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទកភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លង

ចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០២១ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់លើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដា ម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី២ ឆ្នាំ២០២២ មានការកើនឡើងចំនួន ២,៣១ ទ្រីលានរៀល ស្មើនឹង ១០,៤៦% ធៀបនឹងដំណាច់ឆ្នាំ២០២១។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

អត្រាប្តូរប្រាក់រៀលខ្មែរ (KHR) ធៀបនឹងប្រាក់ដុល្លារអាមេរិក (USD) នៅរក្សាស្ថិរភាពល្អ កត្តានេះបានជួយជំរុញកម្លាំងទិញ និងកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងនៃអតិផរណា។ សម្រាប់ត្រីមាសទី២ ឆ្នាំ២០២២ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានការប្រែប្រួលក្នុងចន្លោះពី ៤.០៧០-៤.០៩២ ក្នុងមួយដុល្លារអាមេរិក ដែលបានឡើងថ្លៃបន្តិច បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ក្នុងចន្លោះពី ៤.០៧១-៤.១០៨ ក្នុងមួយដុល្លារអាមេរិក)។ អត្រាប្តូរប្រាក់រៀល ត្រូវបានរំពឹងថានឹងបន្តរក្សាស្ថិរភាពមានតម្លៃជាមធ្យមប្រហែល ៤.០៨៥ រៀលក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ២០២២ ដោយយោងលើនិន្នាការទីផ្សារ (តម្រូវការធៀបនឹងការផ្គត់ផ្គង់មានភាពប្រហាក់ប្រហែលគ្នា) ហើយលើសពីនេះ ស្ថិតក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់របស់ធនាគារជាតិ នៃ កម្ពុជា ដើម្បីរក្សាស្ថិរភាពតម្លៃ និងទំនុកចិត្តពីសាធារណជន ក្នុងការប្រើប្រាស់ប្រាក់រៀល។ ចំពោះ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអនុវត្តយ៉ាងម៉ឺងម៉ាត់ តាមបទប្បញ្ញត្តិច្បាប់ដែលបានតម្រូវ និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន។ ធនាគារបានធ្វើការវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងជារៀងរាល់ថ្ងៃ ដើម្បីចាត់វិធានការទាន់ពេលវេលាតាមការចាំបាច់។ ដូច្នេះ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ចំពោះធនាគារឡើយ។

ចំពោះអត្រាការប្រាក់នៃទីផ្សារក្នុងស្រុក បានបន្តប្រែប្រួលបន្តិចបន្តួចក្នុងរង្វង់នៃការប្រកួតប្រជែងក្នុងសកម្មភាពជំនួញ។ ធនាគារបាន និងកំពុងដំណើរការអាជីវកម្មរបស់ខ្លួនដោយផ្អែកស្ទើរតែទាំស្រុងលើអត្រាការប្រាក់ថេរ ទាំងប្រាក់បញ្ញើនិងប្រាក់កម្ចី ដែលមានទំនាក់ទំនងដោយប្រយោលតិចតួចប៉ុណ្ណោះ ជាមួយនឹងបម្រែបម្រួលអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ ដូច្នេះផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារគឺតិចតួចបំផុត ហើយការប្រែប្រួលនេះស្ថិតក្នុងការត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការដោះស្រាយឱ្យបានសមស្របនិងទាន់ពេលវេលា ចៀសវាងបាននូវផលប៉ះពាល់ដល់លទ្ធផលនៃអាជីវកម្មរបស់ធនាគារ។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodity) ធនាគារមិនមានផ្តល់សេវាបែបនោះទេ។

## ង- ផលប៉ះពាល់នៃអតិផរណា

អតិផរណាសម្រាប់ឆ្នាំ២០២២ ត្រូវបានព្យាករថានឹងកើនឡើងក្នុងរង្វង់ប្រហែល ៥% ដោយសារតែកំណើននៃតម្លៃប្រេងលើទីផ្សារអន្តរជាតិ និងការកើនឡើងនៃតម្លៃទំនិញផ្សេងៗទៀត ដែលបណ្តាលមកពីសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន។ ដូច្នេះ វានឹងមានផលប៉ះពាល់ខ្លះដល់ការចំណាយរបស់អ្នកប្រើប្រាស់ ប៉ុន្តែផលប៉ះពាល់នោះនឹងត្រូវបានទូរទាត់ដោយការរំពឹងទុកនៃការងើបឡើងវិញនៃសេដ្ឋកិច្ច។ ទោះយ៉ាងណា ប្រតិបត្តិការរបស់ធនាគារមិនជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ដូច្នេះហើយ មិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ធនាគារឡើយ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ច៖**

ផ្អែកតាមរបាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់ ធនាគារជាតិ នៃ កម្ពុជា បានបញ្ជាក់បន្ថែមថា កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ នឹងសម្រេចបានក្នុងរង្វង់ ៥,៣% ដោយគាំទ្រដោយវិស័យចម្បងនានារួមមាន (១) វិស័យកាត់ដេរត្រូវបានរំពឹងថានឹងមានកំណើន ៩,៦% គាំទ្រជាចម្បងដោយភាពប្រសើរឡើងនៃតម្រូវការខាងក្រៅ គួបផ្សំនឹងវិធានការគាំទ្ររបស់រដ្ឋាភិបាល។ (២) វិស័យសំណង់រំពឹងថាមានកំណើនទាប ១,២% ដែលគាំទ្រដោយកំណើនលំហូរទុនវិនិយោគបរទេស តម្រូវការក្នុងស្រុក និងឥណទានទៅកាន់វិស័យសំណង់។ (៣) វិស័យកសិកម្មត្រូវបានព្យាករថាមានកំណើន ១,២% រួមចំណែកដោយភាពអំណោយផលនៃកត្តាអាកាសធាតុ ការចូលជាធរមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី។ (៤) វិស័យទេសចរណ៍ ត្រូវបានរំពឹងថាមានកំណើនដល់ ៦,១% ដោយសារការដកចេញវិធានសុខាភិបាលសម្រាប់ការធ្វើដំណើរមកកម្ពុជា និងការដាក់ចេញផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍។ (៥) វិស័យហិរញ្ញវត្ថុ ជាពិសេសគឺវិស័យ ធនាគារ ចូលរួមគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈការផ្តល់ហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុនានាដោយឥណទានត្រូវបានរំពឹងថានឹងមានកំណើនក្នុងអត្រា ២៣% គួបផ្សំនឹងការបន្តអនុវត្តវិធានការគាំទ្រដទៃទៀត។ ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើងដល់ ៥,៦% សម្រាប់ឆ្នាំ២០២២ និងដោយមានការចូលរួមចំណែកពីវិស័យកសិកម្មដែលបានដាក់ក្តីរំពឹងថានឹងកើនឡើង១,៣% វិស័យកាត់ដេរព្យាករថាកើន ៨,១% វិស័យកម្មន្តសាលមិនមែនកាត់ដេរកើនចំនួន ១២,២ % វិស័យដឹកជញ្ជូន និងគមនាគមន៍ចំនួន ៦,២% វិស័យសំណង់កើនចំនួន ៥,៤% វិស័យអចលនទ្រព្យកើន ៤,១% វិស័យលក់ដុំ-រាយកើនចំនួន ៥% វិស័យសណ្ឋាគារ និងភោជនីយដ្ឋានកើនចំនួន១២% និងវិស័យផ្សេងៗទៀត កើនចំនួន ៤,៣%។ [(១),(២),(៣)]

ស្ថាប័នល្បីល្បាញមួយចំនួនក៏បានព្យាករអំពីកំណើន GDP របស់កម្ពុជាផងដែរ ដោយបន្តរក្សាតួលេខនៃការព្យាកររៀងៗខ្លួន ដូចគ្នាទៅនឹងត្រីមាសទី១ ឆ្នាំ២០២២ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករថា សេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង ៥,៣% នៅឆ្នាំ២០២២ និង ៦,៥% នៅក្នុងឆ្នាំ២០២៣ ដោយផ្តោតជាចម្បងទៅលើភាពខ្លាំងលើការនាំចេញទំនិញ និងលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២ របស់កម្ពុជាថា នឹងកើនឡើង ៥,១% នេះបើយោងទៅតាមគេហទំព័រផ្ទាល់របស់ស្ថាប័ននេះ។ ធនាគារពិភពលោកបន្តព្យាករថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់ឆ្នាំ២០២២ ត្រូវបានរក្សានៅកម្រិត ៤,៥% ក្រោមសេណារីយ៉ូមូលដ្ឋានរបស់ខ្លួន បើទោះបីជាតម្រូវការពិភពលោកធ្លាក់ចុះ ដោយសារតែការរឹតបន្តឹងលើការធ្វើដំណើរដែលជំរុញដោយ អត្រាចាក់វ៉ាក់សាំងកូវីដ-១៩ ជាតិខ្ពស់ក៏ដោយ។ [(៤),(៥),(៦)]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ (១) បន្តពង្រឹងការអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។ (២) បន្តការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី ដោយចាប់ផ្តើមបើកការពិភាក្សាកម្រិតក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីឱ្យការរៀបចំមានភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា ព្រមទាំងឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នីត្យានុកូលភាព និងសង្គតិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៣) រៀបចំយន្តការដើម្បីគ្រប់គ្រងចំណូលក្នុងវិស័យធំៗដែលជាសក្តានុពលសម្រាប់ ចំណូលពន្ធ រួមមាន៖ (ក) បន្តពង្រឹងការអនុវត្តកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិអាល់កុលរបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter), (ខ) ពង្រឹងកិច្ចសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC), (គ) រៀបចំយន្តការកំណត់អត្តសញ្ញាណអចលនទ្រព្យ (Property ID) ដើម្បីបញ្ជាក់ថាអចលនទ្រព្យនីមួយៗបានបង់ពន្ធរួចរាល់ ចៀសវាងការលក់ដូរអចលនទ្រព្យដោយមិនបានបង់ពន្ធ, (ឃ) រៀបចំធ្វើទំនើបកម្មយន្តការត្រួតពិនិត្យតាមដានការដឹកជញ្ជូនផលិតផលតេលសិលា និងគ្រឿងសំណង់ តាមរយៈការដំឡើងឧបករណ៍តាមដាន (GPS និង RFID) តាមរថយន្តដឹកជញ្ជូននិងស្ថានីយ ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលមានអភិបាលកិច្ចល្អជាស្នូល ការលើកកម្ពស់អនុលោមភាព និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាព, (ង) រៀបចំយន្តការសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធើណែត (ISPs) ដែលកំពុងប្រតិបត្តិការក្នុងស្រុក ដើម្បីចាត់វិធានការគ្រប់គ្រងលើ

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce)។ (៤) បន្តពង្រឹង ការអនុវត្តវិធានការទារបំណុលពន្ធរាំរ៉ៃ និងគោរពស្នើសុំគោលការណ៍សម្រេចទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះករណីសហគ្រាសរឹងរូសពុំព្រមចូលខ្លួនមកទូទាត់បំណុលពន្ធ។ (៥) បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធលើវិស័យដែលនៅមានសក្តានុពល ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាព។ (៦) ជំរុញសហគ្រាសក្នុងវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) ឱ្យចូលខ្លួនមកចុះបញ្ជីពន្ធដារ និងអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។ (៧) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីតាមរយៈការអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ។ (៨) បន្តពង្រឹងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ កំណែទម្រង់ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ និងបន្តពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការរៀបចំកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (Tax Education) កិច្ចប្រជុំ សិក្ខាសិលាវិបស្សនា គេហទំព័រ ទំព័រទំនាក់ទំនងសង្គម និងការផ្សាយផ្ទាល់តាមអនឡាញ ជាពិសេសការរៀបចំកម្មវិធី “ពន្ធដារកម្ពុជា” ដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់តាមប្រព័ន្ធបណ្តាញសង្គម GDT Facebook Live, សេវាឆ្លើយតបតាមប្រព័ន្ធទូរស័ព្ទ Call Center ១២៧៧, កម្មវិធី GDT Live Chat ជាដើម។ (៩) បន្តការងារកែទម្រង់ធនធានមនុស្ស និងបន្តពង្រឹងការអនុវត្តច្បាប់វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។ [៧]

សម្រាប់រយៈពេល៦ខែដំបូង នៃឆ្នាំ២០២២ ចំណូលពន្ធ-អាករសរុប ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៧.៩៨០,៥៧ ប៊ីលានរៀល (ប្រមាណជា ១.៩៧០,៥១ លានដុល្លារអាមេរិក) ស្មើនឹង ៦៩,៨៩% នៃផែនការច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២២ និងបើធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា នាឆ្នាំមុន ឃើញថាកើនឡើងចំនួន ១.៨៣៣,៥៩ ប៊ីលានរៀល (ប្រមាណជា ៤៥២,៧៤ លានដុល្លារអាមេរិក) ឬស្មើនឹង ២៩,៨៧%។ គួរកត់សម្គាល់ផងដែរថា បើធៀបទៅនឹងរយៈពេល៦ខែដូចគ្នា ឆ្នាំ២០២១ ចំណូលពីប្រភេទពន្ធសំខាន់ៗរួមមានពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម អាករពិសេស ពន្ធលើប្រាក់បៀវត្ស ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ និងពន្ធលើឈ្នួលផ្ទះនិងដី បានរក្សាកំណើនរៀងគ្នាចំនួន ២៧,១៩% ៣៣,៣៧% ៣៤,០១% ២៥,១៦% ៤៤,៣៨% និង ១០,១២%។ ចំពោះលទ្ធផលប្រមូលពន្ធក្នុងខែមិថុនា ឆ្នាំ២០២២ បានបង្ហាញថាចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងមានចំនួន ៩៨៦,១០ប៊ីលានរៀល (ប្រមាណជា ២៤៣,៤៨លានដុល្លារអាមេរិក ឬស្មើនឹង ៨,៦៤% នៃផែនការច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២) កើនឡើងចំនួន ៣០៧,២៩ ប៊ីលានរៀល (ប្រមាណជា ៧៥,៨៧ លានដុល្លារអាមេរិក ឬស្មើនឹង ៤៥,២៧%) បើប្រៀបធៀបនឹងចំណូលពន្ធ-អាករប្រចាំខែមិថុនា ឆ្នាំ២០២១។ [៨]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖ (១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ (៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង (៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [៩]

សម្រាប់ឆមាសទី១នេះ រូបិយវត្ថុទូទៅ (M2) ត្រូវបាន ប៉ាន់ស្មានថាកើនឡើង ១៤,៣% (ឆ្នាំលើឆ្នាំ) ដែលគាំទ្រដោយកំណើនប្រាក់បញ្ញើជារៀលចំនួន ១៨,៩% និងប្រាក់បញ្ញើជារូបិយប័ណ្ណចំនួន ១៥,៦% ខណៈដែលរូបិយវត្ថុក្នុងចរាចរណ៍មានកំណើនទាបត្រឹម ០,៩%។ ធនាគារជាតិនៃកម្ពុជាបានរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិត ៧% (ទាំងប្រាក់បញ្ញើជារៀល និងរូបិយប័ណ្ណបរទេសនិងកម្ចីអនិវាសជន ដោយរូបិយប័ណ្ណថយចុះពី ១២,៥% និងជារៀលថយចុះពី ៨%) មកនៅត្រឹម ១៤,៤ ទ្រីលានរៀល (ជាដុល្លារអាមេរិក ៣,៣ ប៊ីលានដុល្លារអាមេរិក និងជារៀល ១,១ ទ្រីលានរៀល) ដើម្បីបន្តគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យមានសន្ទនីយភាពបន្ថែម សម្រាប់ផ្តល់ឥណទានទៅដល់វិស័យនានាដែលកំពុងត្រូវការ បន្ទាប់ពីការធូរស្រាលនៃវិបត្តិជំងឺកូវីដ-១៩។ សន្ទនីយភាពលើសក្នុងប្រព័ន្ធធនាគារត្រូវបានស្រូបយកមកវិញ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) សរុបចំនួន ៦៨,៧ ទ្រីលានរៀល (ស្មើនឹង ១៦,៩ ប៊ីលានដុល្លារអាមេរិក (ក្នុងនោះ NCD ជាប្រាក់ដុល្លារអាមេរិក មានចំនួន ១៤,៩ ប៊ីលានដុល្លារអាមេរិក និងជារៀលមានចំនួន ៨,៤ ទ្រីលានរៀល) ដែលបានកើនឡើង ១,៤% (NCD ជាប្រាក់ដុល្លារ

អាមេរិកថយចុះ ១,២% និងជារៀលកើនឡើង ២៤,៣%) ខណៈដែលការបញ្ចេញសន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) មានចំនួន ៨៥០ ប៊ីលានរៀល (ឥណប្រតិទាន៩១ថ្ងៃ មានចំនួន ២៤០ប៊ីលានរៀល, ឥណប្រតិទាន១៨២ថ្ងៃ មានចំនួន ៣១០ប៊ីលានរៀល និង ឥណប្រតិទាន៣៦៤ថ្ងៃ មានចំនួន ៣០០ប៊ីលានរៀល) ដែលបានថយចុះជិត ៤ដង ដើម្បីរួមចំណែករក្សាស្ថិរភាពអត្រាប្តូរប្រាក់។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់សន្ទនីយភាពជាប្រាក់រៀលចំនួន ៨០០លានរៀល តាមរយៈឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)។ [១]


ឯកសារយោងៈ

(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Semi%20Annual%20Report%202022_KHVersion.pdf

(២) https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6/ 20220411-%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6-%E1%9E%9F%E1%9E%84%E1%9F%92%E1%9E%82%E1%9E%98-%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85

(៣) https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6/20220218-%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6-%E1%9E%9F%E1%9E%84%E1%9F%92%E1%9E%82%E1%9E%98%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85%E1%9E%96%E1%9E%B6%E1%9E%8E%E1%9E%B7%E1%9E%87%E1%9F%92%E1%9E%87%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98

(៤) https://www.adb.org/news/cambodia-economy-accelerate-2022-and-2023-adb

(៥) https://www.imf.org/en/Countries/KHM#whatsnew

(៦) https://www.thestar.com.my/aseanplus/aseanplus-news/2022/04/06/cambodia-maintains-gdp-growth-at-45-for-2022-world-bank

(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/c8e3215e-98ef-4dc0-9b95-5b1bf767741e

(៨) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/8bfab18c-f289-4264-84d2-48c677cc64ea

(៩) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202021%20Publish.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃអង្គារ ១២កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២

បានអាន និងឯកភាព

ហត្ថលេខា

ធនាគារ អេស៊ីលីដា ភីអិលស៊ី

ACLEDA BANK PLC.

**ឆាយ សឿន**

អេស៊ីលីដា
ACLEDA BANK